ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ១៤៤/០៩-ភីស៊ីស៊ីអេស

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: សុង វណ្ណស៊ីន

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន ភីស៊ីស៊ីអេស ហ្គាមិន លីមីធីត

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ២៧៣ ៦១៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក យូ ប៉េងទ្រី ប្រធានរដ្ឋបាលក្រុមហ៊ុន

២- លោក ប៉ាន រស្មី បុគ្គលិករដ្ឋបាលក្រុមហ៊ុន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : គ្មាន

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០៨៩ ២៨៩ ៣៤២ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិតៈ

| | |
|---|---|
| ១- លោក ម៉ុម ធន | អ្នកដោះស្រាយវិវាទ សហព័ន្ធសហជីពខ្មែរ |
| ២- លោក ឃិន វាសនា | ប្រធានសហជីពខ្មែរ |
| ៣- លោកស្រី វឿម ពៅ | កម្មករ |
| ៤- លោកស្រី ម៉ៅ វីរភាព | កម្មករ |
| ៥- លោកស្រី ទេព សុភា | កម្មករ |
| ៦- លោកស្រី វ៉ិន ចន្ថា | កម្មករ |
| ៧- លោកស្រី ឈួន សុភ័ណ្ឌ | កម្មករ |
| ៨- លោកស្រី កើត ចន្ទី | កម្មករ |
| ៩- លោកស្រី សូ ស្រីមុំ | កម្មករ |
| ១០- លោកស្រី ហៃ ហេង | កម្មករ |
| ១១- លោកស្រី ឈួន ហ៊ី | កម្មករ |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតផ្នែកដេរ ក្រុម២៧ និង ២៨ ចំនួន ៦៥ នាក់ នៅតែទាមទារឱ្យក្រុមហ៊ុនរក្សាក្រុមពួកគាត់ឱ្យនៅដដែល ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចរក្សាក្រុម២៧ និង ២៨ ឱ្យនៅដដែលបានទេ ។

២- កម្មករនិយោជិតផ្នែកដេរ ក្រុម ២៧ និង ២៨ ចំនួន ៦៥ នាក់ ទាមទារឱ្យក្រុមហ៊ុនបង្រួមក្រុម ២៧ និង ២៨ ឱ្យទៅជាក្រុមតែមួយ ។ ដោយឡែកភាគីក្រុមហ៊ុនពុំអាចបង្រួមក្រុម ២៧ និង ២៨ ឱ្យនៅក្រុមតែមួយបានទេ ។

៣- កម្មករនិយោជិតផ្នែកដេរ ក្រុម ២៧ និង ២៨ ចំនួន ៦៥ នាក់ ទាមទារនៅពេលដែលក្រុមហ៊ុនពុំព្រមរក្សាក្រុមពួកគាត់ឱ្យនៅដដែល ឬបង្រួមក្រុម ២៧ និង ២៨ ទៅជាក្រុមតែមួយ សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់ផ្សេងៗតាមច្បាប់ស្តីពីការងារ ។ ដោយឡែកភាគីក្រុមហ៊ុនពុំអាចផ្តល់ជូនតាមការទាមទារខាងលើបានទេ ។

## សមត្ថកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានសមត្ថកិច្ចក្នុងការចេញសេចក្តីសម្រេចនេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ

នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៥០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ (អាណត្តិទី២) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៩៧៣ ក.ប/អក/វ.ក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៥ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទនៃកិច្ចប្រជុំមុនសវនាការ :** ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៥ (វេលាម៉ោង ១៥:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់ក្រុមហ៊ុនចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៥ ស្នើសុំអន្តរាគមន៍ស្តីពីករណីកម្មករនិយោជិតធ្វើកូដកម្ម ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីធ្វើការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ភីស៊ីស៊ីរេស នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ដោយបានទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ០៣ ចំណុច លើការទាមទារចំនួន ០៣ ចំណុច ។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ៩៧៣ ក.ប/អក/វ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដូច្នេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងរៀបចំការប្រជុំមុនសវនាការមួយរវាងក្រុមប្រឹក្សាអាជ្ញាកណ្តាលជាមួយនឹងភាគីវិវាទ ដែលធ្វើឡើងនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៥ វេលាម៉ោង ៣:០០ នាទីរសៀល ។ នៅក្នុងកិច្ចប្រជុំមុនសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់ភាគីពីនីតិវិធីដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបានបញ្ជាក់ថា ក្នុងករណីដែលកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចបន្តនីតិវិធីដោះស្រាយវិវាទការងារនេះបានទេ ។ បន្ទាប់ពីពន្យល់ភាគីវិវាទពីនីតិវិធីនេះហើយ ភាគីទាំងពីរបានព្រមព្រៀងលើការពន្យល់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទៅពិចារណាក្នុងការដោះស្រាយវិវាទ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ដល់ភាគីទាំងពីរផ្តល់លទ្ធផលនៃការសម្រេចរបស់ខ្លួនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រឹមថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៥ ។

ប៉ុន្តែមកដល់ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ ភាគីកម្មករនិយោជិត និងនិយោជកមិនអាចរកដំណោះស្រាយការណ៍វិវាទរបស់ខ្លួនបានទេ ហើយកម្មករនិយោជិតក៏រក្សាជំហរក្នុងការបន្តធ្វើកូដកម្មទៀត ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាមួយ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ឱ្យកម្មករនិយោជិតផ្អាកជាបន្ទាន់នូវសកម្មភាពកូដកម្មរបស់ខ្លួន ប៉ុន្តែភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនស្តាប់តាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោម :

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតរបស់នាយកក្រុមហ៊ុន ភីស៊ីស៊ីអេស គោរពជូន លោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការស្នើសុំជួយដោះស្រាយបញ្ហាដែលកម្មករធ្វើកូដកម្មក្នុងបក្សនេះ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៩ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត : គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ភីស៊ីស៊ីអេស លេខ ៩៧៣ ក.ប/អក/វក ចុះ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ភីស៊ីស៊ីអេស ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៩ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៧៥៤ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៧៥៥ កប/អក/វក/លកអ. ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ។

៣- សេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០១៣/០៩ កអក. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ។

**មូលហេតុ**

មិនមានការរកឃើញមូលហេតុទាក់ទងទៅលើចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជាដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយហេតុនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន ។

ហេតុផលនៃសេចក្តីសម្រេច

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមពន្យល់ពីនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបានចេញបញ្ជាឱ្យកម្មករនិយោជិតបញ្ឈប់កូដកម្មក៏ដោយ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១៤៤/០៥- ភីស៊ីស៊ីអេស នេះដែរឬទេ?

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា *"ក្នុងកំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាកវាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀតដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"* ។

បន្ថែមលើនេះទៀត នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកកំពុងធ្វើឡុកអៅ ។

ទាក់ទងនឹងការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្នុងដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ បានរកឃើញយុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដូចខាងក្រោម:

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៤/០៤-វីប អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ ចែងថា *"ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្មក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួម ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាននៅពេលណាដែលគោរពដឹង កម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម"* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រូរ៉ង់កូ ទីតធីង ប្លាហេន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា *" នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ"* ។

នៅក្នុងសំណុំរឿងលេខ ២៨/០៦ ជី ឌី វីអ និងសំណុំរឿងលេខ ៣៤/០៦-ណេមេរ៉ូក ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងទាំងនោះ ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល (*សូមមើលបន្ថែមក្នុងសេចក្តីបង្គាប់អាជ្ញា*

*ករណីលេខ ៩៧/០៧-ស៊ូត វ៉ី, លេខ ៦៣/០៨-តៅវ៉ាន់ធី ហ៊ីរ និងករណីលេខ ១៣៧/០៩ និង ១៣៨/០៩-ញូ ភាញ់ ) ។*

ផ្អែកលើការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងលេខ ១៤៤/០៩-ភីស៊ីស៊ីអេស នេះ ពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថា ពួកគេមានបំណងយកវិវាទការងាររួមនេះ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ព្រោះភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ហើយមិនគោរពតាមបញ្ជា និងការស្នើសុំរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ហេតុដូច្នេះ ដើម្បីឱ្យស្របគ្នាទៅនឹងច្បាប់ ព្រមទាំងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា មិនបន្តដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះទេ ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ :

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១៤៤/០៩-ភីស៊ីស៊ីអេស ។

### ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : ស៊ុខ សុខី

ហត្ថលេខា: ------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : សុខ ចន្ទស៊ីន

ហត្ថលេខា: ------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : គង់ ផល្លះ

ហត្ថលេខា: ------------------------